BMI0123

# សម្ភាសន៍ជាមួយ វ៉ាន់ សាវឿន ភេទស្រី អាយុ៥៩ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ ប្រធានកងតូច

## ស្រុកកំណើតនៅភូមិពន្ធ្រ ឃុំស្ពានស្រែង ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ

## សព្វថ្ងៃរស់នៅភូមិថ្មដែកកេះ ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយ ៖ ផា ផល្លា

០០:៥១:៥៨

២៧ទំព័រ

ផល្លាៈ អត់អីទេពួកខ្ញុំគ្រាន់តែចង់ដឹងពីប្រវត្តិលោកពូផ្ទាល់តែម្តង ថាពូធ្លាប់ឆ្លងកាត់អីខ្លះកាលណ្ហឹង ម៉េចអីចឹង ។

សាវឿនៈ ឆ្លងកាត់ៗតែសម័យគស៊ូនិយាយរួមសម័យលន់ នល់ ។

ផល្លាៈ សម័យលន់ នល់ពូធ្វើអីគេដែរពូ?

សាវឿនៈ ខ្ញុំធ្វើកងទ័ពយោធា ។

ផល្លាៈ ខ្ញុំសូមសួបន្តិចលោកពូឈ្មោះអីដែរ នៅភូមិឃុំអីដែរ?

សាវឿនៈ ភូមិកំណើតខ្ញុំនៅខាងស្រុកណ្ហឹងនាង ប៉ុន្តែសព្វថ្ងៃខ្ញុំបានប្រពន្ធនៅភូមិបន្ទាយឆ្មា ។

ប៊ុនថនៈ នៅភូមិអីដែរ?

សាវឿនៈ ភូមិពន្ធ្រ ឃុំស្ពានស្រែង ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ។

ផល្លាៈ លោកពូឈ្មោះអីដែរលោកពូ?

សាវឿនៈ វ៉ាន់ សាវឿន ។

ផល្លាៈ លោកពូឆ្នាំនេះអាយុប៉ុន្មានដែរ?

សាវឿនៈ ខ្ញុំ?

ផល្លាៈ ចា៎!

សាវឿនៈ ខ្ញុំអាយុ៥៩ឆ្នាំ ។

ផល្លាៈ ពូមានកូនប៉ុន្មាននាក់?

សាវឿនៈ កូន៥នាក់ ។

ផល្លាៈ ចា៎! ចុះកាលនៅជំនាន់លន់ នល់ណ្ហឹងលោកពូធ្វើគេដែរ?

សារឿន៖ ខ្ញុំធ្វើខ្មែរក្រហមតស៊ូ ។

ផល្លា៖ ចាំ! ហើយគ្រួសារលោកពូណ្ហឹងម៉េចដែរ?

សារឿន៖ ខ្ញុំទើបតែបានប្រពន្ធក្រោយពេលរំដោះហើយ ។

ផល្លា៖ ចុះឪពុកម្ដាយអី?

សារឿន៖ ឪពុកម្ដាយខ្ញុំស្លាប់អស់ហើយ ។

ផល្លា៖ ស្លាប់តាំងពីជំនាន់ណាលោកពូ?

សារឿន៖ ឪពុកស្លាប់តាំងពីជំនាន់៦៨ ។

ផល្លា៖ ៦៨?

សារឿន៖ បាទ! ហើយម្ដាយស្លាប់៨០ដាង ។

ផល្លា៖ ចុះឪពុកពូស្លាប់ដោយសារអី?

សារឿន៖ ឪពុកម្ដាយខ្ញុំស្លាប់ដោយសារចាស់ ចាស់ជរាទាំងអស់ ។

ផល្លា៖ ចាំ!

សារឿន៖ ទាំងឪពុកទាំងម្ដាយស្លាប់ដោយសារចាស់ ។

ផល្លា៖ ហើយលោកពូម៉េចបានចូលធ្វើទាហានខ្មែរក្រហមនៅជំនាន់លន់ នល់ចឹងលោកពូ?

សារឿន៖ សម័យតស៊ូណ្ហឹងវាថាមិនបានណាំកូន ពីសម័យនោះគឺគេថាឲ្យទៅតស៊ូណាំ ។

ផល្លា៖ ពីណាហៅពូចូលខ្មែរក្រហម ពីណាហៅបុក៏ពូស្ម័គ្របុម៉េចលោកពូ?

សារឿន៖ ទេពេលណ្ហឹងគេរើសទាហាន ។

ផល្លា៖ គេរើសទាហាន?

សារឿន៖ មួយឆ្នាំបីខែ ។

ផល្លា៖ ចាំ!

សារឿន៖ ធ្វើនៅក្រុមបែកចាន ។

ផល្លា៖ នៅក្រុមបែកចានណ្ហឹងនៅណាពូ ខេត្តអីគេ?

សារឿន៖ ខេត្តបាត់ដំបងយើងណ្ហឹង?

ផល្លា៖ ចាំ!

សារឿន៖ ដល់ពេលគេទម្លាក់សីហនុភ្លាម ក៏កងទ័ពគេធ្វើរដ្ឋប្រហាហើយណោះ?

ផល្លា៖ ចាំ!

សារឿន៖ ធ្វើរដ្ឋប្រហាភ្លាមក៏គេអូសទាញចូលខ្ញុំគ្មានទៅសុំអីផង ។

ផល្លា៖ ចឹងទៅក្នុងជំនាន់លន់ នល់នៅពេលដែលពូធ្វើខ្មែរក្រហមណ្ហឹងគេឲ្យលោកពូធ្វើអីខ្លះ ហើយសកម្មភាពអីខ្លះលោកពូ?

សារឿន៖ ដល់សម័យ៧២ឡើងខ្ញុំគេឲ្យកាន់ប្រធានកងធំ ។

ផល្លា៖ ប្រធានកងធំ? កាន់ទ័ពប៉ុន្មានទៅចឹង?

សារឿន៖ ១០០នាក់ជាង! ដល់សម័យ៧៤ឡើងបានខ្ញុំកាន់កងវរៈសេនាតូចមានប្រហែល៣០០ជាង

ផល្លា៖ ចា៎!

សារឿន៖ ដល់១៧មេសា ចូលដល់ឆ្នាំ៧៥គេហៅថារំដោះបានទូទាំងប្រទេស គេចោទប្រកាន់ថាខ្ញុំនេះគ្រប់គ្រងក្រុមក្បត់ហើយក៏យកក្រុមខ្ញុំទៅសម្លាប់ចោលម្យ៉ា យកទាំងប្ដីទាំងប្រពន្ធ ប្រពន្ធនោះកូនមួយ គេថាក្រុមខ្ញុំនេះក្រុមក្បត់ ។

ផល្លា៖ ចា៎!

សារឿន៖ គេយកទៅសម្លាប់ សំណាងហើយដែលខ្ញុំបានគេចខ្លួនបានរស់ទាំងប្រពន្ធទាំងកូនដល់សព្វថ្ងៃ

ផល្លា៖ ម៉េចបានគេយកទៅចឹងលោកពូ?

សារឿន៖ គេថាខ្ញុំក្រុមក្បត់ ។

ផល្លា៖ ចឹងគេមកយកដល់ផ្ទះហ្មង?

សារឿន៖ បាទ!

ផល្លា៖ ចឹងអាជំនាន់ខ្មែរក្រហមណ្ហឹងគេជម្លៀសលោកពូទៅណាដែរ?

សារឿន៖ បានអីជម្លៀសបើគេយកខ្ញុំទៅសម្លាប់ ។

ផល្លា៖ ចឹង?

សារឿន៖ បាទ! ថាខ្ញុំណ្ហឹងគ្រប់គ្រងក្រុមក្បត់ ។

ផល្លា៖ ចា៎!

សារឿន៖ ដល់ឆ្នាំ១៧មេសាដែលសម្ដេចហ៊ុនសែនរំដោះបាននេះខ្ញុំក៏ប្រាស់ខ្លួនចេញពីក្នុងដីខ្មែរចូលទៅនៅដីថៃ ។

ផល្លា៖ ចា៎! ចុះពូអាជំនាន់៧៥ដែលគេថាយកពូទៅសម្លាប់ណ្ហឹងម៉េចបានពូរួចខ្លួនកើត?

សារឿន៖ គេដល់ខ្ញុំនិយាយស្រួលទៅគេស្ដាប់ពាក្យសំដីខ្ញុំបាន ដែលខ្ញុំនេះល្អ ទៀតត្រង់ ។

ផល្លា៖ គេសួរម៉េចខ្លះទៅលោកពូចឹង?

សារឿន៖ គេសួរចម្លើយថាអ្នកឯងឥតស្លូតពីជំនាន់ណាម៉ោ?

ផល្លា៖ ចា៎!

សារឿនៈ ដល់សួរខ្ញុំរួចខ្ញុំក៏ប្រាប់ដំណើរដើមទង ប្រាប់ដំណើររឿងតាមដែលខ្ញុំបានធ្វើណា៎!

ផល្លាៈ ចា៎!

សារឿនៈ ហើយគេថាចឹងគេទុកអ្នកគស្ញូនៅសិនទៅចឹង ដល់ហើយគេបញ្ជូនខ្ញុំឲ្យទៅនៅកកោះ ។

ផល្លាៈ បញ្ជូនទៅណាលោកពូ?

សារឿនៈ កកោះ!

ផល្លាៈ ភូមិឃុំអីគេអាណ្ហឹង?

សារឿនៈ ភូមិកកោះ ឃុំកកោះ ។

ផល្លាៈ ស្រុកអីលោកពូ?

សារឿនៈ ស្រុកស្វាយចេក ។

ផល្លាៈ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ?

សារឿនៈ បាទ! ខេត្តមានជ័យ ។

ផល្លាៈ គេបញ្ជូនទៅណ្ហឹងឲ្យទៅធ្វើអីគេលោកពូ?

សារឿនៈ ឲ្យទៅធ្វើការប្រូតកាត់ ។

ផល្លាៈ ប្រូតកាត់?

សារឿនៈ បាទ! មួយគ្រួសារខ្ញុំ គ្រួសារខ្ញុំទៅលើកដីអាចម៍គោ លើកដីលើកអី ធ្វើដីធ្វើដំណាំអីចឹង ទៅណា៎ ។

ផល្លាៈ ចឹងលោកពូគេមិនមែនឲ្យធ្វើប្រធានកងប្រធានអីទេ?

សារឿនៈ ទេនាងគេទម្លាក់ចេញ ។

ផល្លាៈ ម៉េចបានគេទម្លាក់ចឹង?

សារឿនៈ ព្រោះតែខ្ញុំក្រុមក្បត់ ។

ផល្លាៈ ចឹង?

សារឿនៈ បាទ! ខ្ញុំក៏ខ្ញុំមិនថាដែរហើយខ្ញុំមិនតូចចិត្តនឹងវាសនាទេ ដល់ពេលអា១៧មេសាឡើងម៉ោះនេះ បានសម្ដេចហ៊ុនសែនរំដោះបានខ្ញុំប្រាស់រត់ទៅ ។

ផល្លាៈ ចុះអានៅជំនាន់ខ្មែរក្រហមលោកពូធ្លាប់ធ្វើដល់ប្រធានកងវរៈសេនាធំអីដែរ ដល់ពេលចូលជំនាន់ខ្មែរក្រហមម៉េចគេទម្លាក់លោកពូចឹង?

សារឿនៈ គេថាខ្ញុំក្បត់ ។

ផល្លាៈ ចឹង?

សារឿនៈ ណ្ហឹងអើយ! ម៉ាភូមិភាគពាយ័ព្យគេថាខ្ញុំក្បត់ទាំងអស់ គេយកទៅសម្លាប់ចោលទាំងអស់ ។

ផល្លាៈ ចុះកាលភូមិភាគពាយ័ព្យណ្ហឹងអ្នកណាគ្រប់គ្រង?

សារឿនៈ រស់ ញ៉ឹម ។

ផល្លាៈ រស់ ញ៉ឹម?

សារឿនៈ បាទ!

ផល្លាៈ ពូដែលឃើញគាត់ទេ?

សារឿនៈ ឃើញ!

ផល្លាៈ ឃើញគាត់ហើយម៉េចដែរលោកពូ?

សារឿនៈ មនុស្សគាត់ល្អ គាត់ចាស់ហើយ គាត់តស៊ូតាំងពីជំនាន់អ៊ីសារៈ ។

ផល្លាៈ ចា៎!

សារឿនៈ មនុស្សគាត់ល្អណាស់ ហើយដល់ពេលដែលខ្ញុំរួចខ្លួនចេញម៉ោ តាំងពីរំដោះ១៧មេសារួច ហើយខ្ញុំក៏បានប្រាស់ខ្លួននៅក្នុងព្រៃ ហើយខ្ញុំក៏បានមករំដោះបងប្អូននៅភូមិឃុំបន្ទាយឆ្មានេះ ធ្វើប៉ារ៉ាមកវ៉ៃនៅទីនេះ វ៉ៃខ្មែរក្រហមនៅទីនេះវ៉ៃរំដោះប្រជាជន ។

ប៊ុនថនៈ ចឹងពូដឹងថារស់ ញ៉ឹមគាត់ចាប់នៅពេលណា?

សារឿនៈ គាត់ចាប់នៅឆ្នាំ៧៧ ។

ប៊ុនថនៈ នៅឆ្នាំ៧៧?

សារឿនៈ បាទ!

ប៊ុនថនៈ ពូមានដឹងថាម៉េចបានគេចាប់គាត់ទេ?

សារឿនៈ គេចោទថាក្បត់ម៉ាភូមិភាគពាយ័ព្យគេចោទថាក្បត់ទាំងអស់ណ្ហឹង គេចោទយើងថាក្បត់ ។

ប៊ុនថនៈ បាទ! ចឹងពូដែលជួបគាត់ទេពូ?

សារឿនៈ ជួបអីបើគាត់ស្លាប់ហើយ ។

ប៊ុនថនៈ អត់ទេនិយាយពីមុនម៉ោ?

សារឿនៈ ជួបតើ!

ប៊ុនថនៈ ដែលនិយាយជាមួយគាត់ដែរទេ?

សារឿនៈ បាទនិយាយ ។

ប៊ុនថនៈ ចឹងកូនគាត់អីពូមានស្គាល់ទេ?

សារឿនៈ ស្គាល់ ។

ប៊ុនថន៖ កូនគាត់ឈ្មោះអីខ្លះ?

សាវឿន៖ កូនដែលធ្លាប់ធ្វើការជួបខ្ញុំមានតែពីនាក់ទេ ។

ប៊ុនថន៖ បាទ!

សាវឿន៖ ខានតាហ៊ីមនេះមួយ តាជានេះពីរ ។

ប៊ុនថន៖ បាទ!

សាវឿន៖ អាហ៊ីមណ្ហឹងគណៈតំបន់ ។

ប៊ុនថន៖ អាហ៊ីមកូនគាត់ដែរ?

សាវឿន៖ កូនក្មួយបង្កើត អាជាបានកូនបង្កើត ។

ប៊ុនថន៖ បាទ!

សាវឿន៖ អាជានោះក៏ស្លាប់ដែរ ។

ប៊ុនថន៖ បាទ! ចឹងប្រពន្ធជាណ្ហឹងពូមានស្គាល់ទេ?

សាវឿន៖ ខ្ញុំអត់ស្គាល់ទេឈ្មោះទេ ។

ប៊ុនថន៖ អត់ស្គាល់គាត់ទេ តែធ្លាប់ជួបដែរ?

សាវឿន៖ បាទ! ធ្លាប់ជួបព្រោះគាត់ធ្វើស្នូលគណៈបក្ស ។

ប៊ុនថន៖ ប្រពន្ធគាត់ណ្ហឹង?

សាវឿន៖ ទេជាណ្ហឹង ។

ប៊ុនថន៖ បាទ!

សាវឿន៖ ស្នូលបក្សសម្ព័ន្ធ ។

ប៊ុនថន៖ បាទ! ចឹងប្រពន្ធគាត់មានដឹងថាកូនពីណាទេពូ?

សាវឿន៖ មិនដឹងទេ អត់ស្គាល់ទេ!

ប៊ុនថន៖ ចឹងជាណ្ហឹងក៏ស្គាល់ពូច្បាស់ដែរ?

សាវឿន៖ បាទស្គាល់ច្បាស់តែគាត់ស្លាប់ហើយគេសម្លាប់ចោលអស់ហើយ ។

ផល្លា៖ សម្លាប់ពីអន្កាល់ពូ?

សាវឿន៖ សម្លាប់កាលឆ្នាំ៧៨ ។

ផល្លា៖ ៧៨?

សាវឿន៖ បាទ! រត់មួយចំនួនរស់ យើងរត់ចេញពីដីខ្មែរគេសម្លាប់ចោលអ្នកដែលគេចាប់បាន ។

ផល្លា៖ ចុះពេលដែលគេហៅទៅសម្លាប់ណ្ហឹងគេប្រាប់ថាម៉េច?

សារឿនៈ គេមិនប្រាប់ថាម៉េចទេគេប្រាប់ថាទៅរៀនសូត្រ ។

ផល្លាៈ ទៅរៀនសូត្រនៅភូមិឃុំណា?

សារឿនៈ (ស្តាប់អត់បាន) ។

ប៊ុនថនៈ ចុះជាអីណ្ហឹងចាប់នៅពេលណា ក្រោយតាញឹម?

សារឿនៈ បាទក្រោយ ។

ប៊ុនថនៈ ក្រោយគាត់?

សារឿនៈ បាទ!

ប៊ុនថនៈ ចុះហ៊ឹម?

សារឿនៈ ចាប់ដំណាលគ្នា ។

ប៊ុនថនៈ ដំណាលគ្នា?

សារឿនៈ បាទ!

ប៊ុនថនៈ កាលណ្ហឹងហ៊ឹមគាត់ធ្វើអីវិញ?

សារឿនៈ គណៈតំបន់ ។

ប៊ុនថនៈ គណៈតំបន់ប៉ុន្មានពូ?

សារឿនៈ តំបន់៥ យើងនេះ ។

ប៊ុនថនៈ បាទ! ហើយជាកាលណ្ហឹងគាត់ធ្វើអីពូ?

សារឿនៈ គាត់អត់ធ្វើអីទេគាត់ធ្វើគណៈបក្ស ។

ប៊ុនថនៈ ស្រួលគណៈបក្ស?

សារឿនៈ បាទ!

ប៊ុនថនៈ ហើប្រពន្ធគាត់?

សារឿនៈ មិនស្គាល់ទេ! ប្រពន្ធហ៊ឹមក៏មិនស្គាល់ដែរស្គាល់តែគាត់ព្រោះនៅជុំគ្នា ។

ប៊ុនថនៈ ចុះក្រៅពីណ្ហឹងកូនគាត់ប៉ុន្មាននាក់ទៀត?

សារឿនៈ អត់ដឹងទេ!

ប៊ុនថនៈ បាទ! ពូជិតស្និទជាមួយគាត់ទេ ដូចថារាប់អានអីស្គាល់អីចឹងអាស៎?

សារឿនៈ បាទកាលដែលរស់នៅជុំគ្នាស្និទដល់តែបែកទៅចេះតែឆ្ងាយ ។

ប៊ុនថនៈ បាទ!

សារឿនៈ ហើយគេទៅនៅស្វាយខ្ញុំក៏មកយកប្រពន្ធនៅបន្ទាយឆ្មា ។

ប៊ុនថនៈ គាត់នៅខាងស្វាយពូមកបន្ទាយឆ្មា?

សាវឿនៈ បាទ!

ប៊ុនថនៈ ប៉ុន្តែមកដល់ដំបូងហ្នឹងពូធ្វើអី កាលបែកហ្នឹង?

សាវឿនៈ ទេអត់មានធ្វើអីទេ ធ្វើស្រែចំការយើងធម្មតា ។

ប៊ុនថនៈ បាទ! គេជម្លៀសពូម៉ោនេះឬមួយក៏គេបញ្ជូនម៉ោ?

សាវឿនៈ បាទគេបញ្ជូនម៉ោ ។

ប៊ុនថនៈ បញ្ជូនម៉ោច្រើនគ្នាទេពូ?

សាវឿនៈ ទេតែម្នាក់ឯង ។

ផល្លាៈ ចុះអ្នកផ្សេងអត់មានជម្លៀសទៅណាទៅណីទេពូ?

សាវឿនៈ ទេតែម្នាក់ឯង ។

ផល្លាៈ ចុះថាហៅទៅអប់រំហ្នឹងហៅពីណាទៅខ្លះពូ?

សាវឿនៈ បាទ?

ផល្លាៈ ដែលថាហៅពូទៅសម្លាប់ មានមិត្តភ័ក្រ្តមានអីទេពូ?

សាវឿនៈ មិនដឹងទេនាងព្រោះចៅហ្វាយស្រុក ។

ប្រពន្ធៈ ទេដែលគេហៅយកទៅធ្វើការយកទាំងគ្រួសារ យកទាំងខ្ញុំ ហៅទៅមិនដំបូងយកកូនទៅទាំងអស់ដល់នេះគេកសាង គេធ្វើការរួចអីរួចហើយគេសម្លាប់ចោល ដល់ពេលនេះគេបញ្ជូនម៉ោ គេកសាងរួចអីរួចគេអប់រំយើងរួចមិនដឹងយើងខុសអីវារកមុខរកមាត់មិនឃើញដល់នេះគេ បញ្ជូនម៉ោវិញ ។

សាវឿនៈ គេចោទថាយើងក្រុមក្បត់ ប៉ុន្តែវាមិនដឹងខុសអី ។

ប៊ុនថនៈ ឆ្នាំប៉ុន្មានពូពេលដែលយកលោកពូទៅ?

សាវឿនៈ ឆ្នាំ៧៦,៧៧ ប៉ុន្តែយើង៧៩ យើងរំដោះហើយណា៎ ។

ផល្លាៈ ៧៩រំដោះ ។

ប្រពន្ធៈ បានកំណើតកូនមួយមីបងគេ មីបងគេ៧៦ ។

សាវឿនៈ មីបងគេឆ្នាំ៧៦ ឆ្នាំរោង បើមីទីពីរហ្នឹងឆ្នាំមមី ឆ្នាំមមី៧៧ហ្នឹងឯង ។

ផល្លាៈ ចឹងគេហៅទៅទាំងគ្រួសារហ្នឹងទៅឆ្នាំ៧៧ហ្នឹងមែន?

សាវឿនៈ បាទយកទៅពីរដងហ្នឹងខ្ញុំរទេះសេះដឹកទៅ ។

ប្រពន្ធៈ ដល់ម៉ោវិញគេយកកូនបញ្ជូនម៉ោទាំងអស់គ្នា ដល់ម៉ោបានចំនួនមិនបាន៣ថ្ងៃផងគេហៅទៅវិញ ដល់គេហៅទៅវិញបងប្អូនម៉ែឪណ្ហើងយកកូនទុកមួយថាបើគេសម្លាប់ចោលយ៉ាងណាឲ្យបានសល់កូនមួយ ។

ប៊ុនថនៈ ខាងណាអ្នកយកពូទៅ?

ប្រពន្ធៈ ពួកខាងកសិកណ្ហើង ខាងសហករណ៍គេខាងស្រុកតែយើងមិនស្គាល់ ។

ផល្លាៈ ខាងស្រុកអីវិញ?

សាវឿនៈ ខាងស្រុកថ្មពួក កងបន្ទាយឆ្មាណ្ហើងឯងដែលគេចាប់យើងបញ្ជូលនោះ ។

ប៊ុនថនៈ ចាប់យកទៅណាវិញពូ?

សាវឿនៈ ចាប់យកទៅសម្លាប់ចោល ដល់នេះគេបញ្ជូនខ្ញុំទៅកកោះ លើកទីពីរបានបញ្ជូនខ្ញុំទៅកកោះបានខ្ញុំមានជីវិត ហើយ១៧មេសាដែលហ៊ុនសែនឲ្យកងទ័ពវៀតណាមចូលម៉ោនេះខ្ញុំក៏បានគេចខ្លួនផុតម៉ោជាមួយម៉ែវានេះ ។

ប្រពន្ធៈ គេហៅទៅធ្វើការនៅកន្លែងកកោះនោះធ្វើពីរដង ដល់សម្រេចចូលបីដងគេបំរុងយកទៅសម្លាប់ចោលរួចទទួលកាប៉ាល់ហោះ អាស៎ទទួលកងទ័ពវៀតណាមម៉ោនោះបានបែកគ្នា ។

ផល្លាៈ ចុះនៅកកោះនោះគេឲ្យធ្វើអីខ្លះអ៊ំ?

ប្រពន្ធៈ គេអត់ឲ្យធ្វើអីទេ គេតាមដានយើង ។

សាវឿនៈ លើកអាចម៌គោធ្វើស្រែ ធ្វើដី ។

ផល្លាៈ គេអត់ឲ្យអ៊ំកាន់អីកាន់អីទៀតទេ?

ប្រពន្ធៈ ខ្ញុំគេឲ្យកិនស្រូវកិនអី អ៊ុំស្រូវដាំបាយដាំអី ។

សាវឿនៈ គេឲ្យដាំបាយដាំទឹកឲ្យគេហូបណា៎ ខ្ញុំទៅនៅណ្ហើងទៅចល័តទៅអីគេណ្ហើង ។

ប្រពន្ធៈ គាត់ក៏ចល័តដែរប្រូត ។

សាវឿនៈ ប្រូតផងធ្វើដីផងមួយយប់ៗស្រេចតែគេបញ្ជានិយាយរួមឲ្យតែបានរស់ ។

ប្រពន្ធៈ គេធ្វើស្រេចតែគេបញ្ជា ។

ផល្លាៈ ចា៎! ចឹងដល់ពេលបែកហើយម៉េចទៀតលោកពូ កាលវៀតណាមចូលម៉ោម៉េចទៀតទៅ?

ប្រពន្ធៈ ដល់នេះក៏វាមិនចប់ វាមិនចប់ទេវានៅតែកម្សត់ខ្ញុំនឹងគ្រួសារ កម្សត់មែនទែនណា៎ដល់ពេលយួនចូលម៉ោហើយវាដេញបាញ់ដល់ដេញបាញ់ទៅតាគាត់ប្រាស់ទៅ ឲ្យតែអ្នកណាធ្វើការ ។

សាវឿនៈ ឲ្យតែអ្នកណាធ្វើខ្មែរក្រហមវាដេញបាញ់ ។

ប្រពន្ធៈ ខ្មែរក្រហមឲ្យប៉ាវ៉ា ដល់ហើយតាគាត់រត់ចូលខាងប៉ាវ៉ា ។

ផល្លាៈ ចឹងពូម៉េចបានគេបាញ់ក្រែងគេថាខាងខ្មែរក្រហម ក្រែងពូធ្វើស្រែធ្វើអីគេថាពូខ្មែរក្រហមដែរ?

សាវឿនៈ ទេនាង! កាលពីដើមឡើយខ្ញុំធ្វើខ្មែរក្រហមដល់មកនេះខ្ញុំធ្វើប៉ាវ៉ា គេថាឲ្យតែប៉ាវ៉ាដេញបាញ់ ទាំងអស់ ។

ផល្លាៈ ចឹងពូចូលប៉ាវ៉ាពីកាលចឹង?

ប្រពន្ធៈ គាត់ចូលប៉ាវ៉ាកំណើតមីឆ្នាំមមី ។

សាវឿនៈ ឆ្នាំ៧៦ ។

ផល្លាៈ ៧៦,៧៧ចូលប៉ាវ៉ា?

សាវឿនៈ បាទ! ឆ្នាំ៧៧ ។

ផល្លាៈ ៧៧ចូលប៉ាវ៉ា?

ប្រពន្ធៈ មិនដឹង៧០ប៉ុន្មានទេចូលប៉ាវ៉ា!

ផល្លាៈ ព្រោះ៧៧នៅខ្មែរក្រហមនៅឡើយណ្ហឹង ។

សាវឿនៈ ណ្ហឹងអើយខ្មែរក្រហមនៅពេញដីនៅឡើយ ។

ផល្លាៈ ចាំ!

សាវឿនៈ គេចូលម៉ោគេវ៉ៃខ្មែរក្រហមតើគេមានវ៉ៃយួនណាំ ។

ប្រពន្ធៈ ដល់ពេលនេះខ្ញុំនៅជាមួយប្រជាជន នៅជាមួយប្រជាជនគាត់នៅមិនបានទេពួកអាម៉ាក់អាម៉ៃនេះឯងគេដេញ ។

សាវឿនៈ ពួកអាប្រធានសហករណ៍!

ផល្លាៈ ប្រធានសហករណ៍ឈ្មោះអីគេពូ?

ប្រពន្ធៈ អាម៉ាក់អាម៉ៃណ្ហឹង ។

ផល្លាៈ ពីរនាក់មែន?

ប្រពន្ធៈ អាម៉ាក់អាម៉ៃ អាសុង អាអ៊ុន អាអ៊ុយនេះឯង ។

សាវឿនៈ ខ្ញុំទៅបាត់មិនបានស្គាល់អស់ទេនាង ។

ផល្លាៈ អ៊ីចូលប៉ាវ៉ាពេលដែលអ៊ីរត់ទៅថៃមែន?

សាវឿនៈ បាទ! រត់ទៅព្រំដែនណ្ហឹងអើយ ។

ប្រពន្ធៈ ប៉ាវ៉ាកន្លែងបន្ទាយតាស្រីស្រែពិលណ្ហឹង ។

ផល្លា៖ ស្រែអំពិលគាសឿនសានណ្ហើងមែន?

សាវឿន៖ បាទ!

ប្រពន្ធ៖ ខ្ញុំដល់បែកបន្ទាយឆ្មានេះឯងពួកអាម៉ាក់អាម៉ាកៀរទៅ ដល់កៀរទៅពួកកងទ័ពនេះចុះមកជួយ ហើយក៏បានដណ្តើមកូនគ្នា ខ្ញុំបានកូនមួយឪខ្ញុំបានកូនមកខាងប្តីខ្ញុំនេះមួយ ខ្ញុំគេប្រមូលទៅផ្សេងណានាងដែលមិនមានប្តីនៅ ដែលខ្ញុំនៅនេះណាមិនមានប្តី ប្តីរត់ចូលប៉ាវ៉ាវា ទុកប្រពន្ធមួយឡែក អ្នកមានប្តីវាកៀរទៅហើយ អ្នកអត់ដូចខ្ញុំនេះគេទុកមួយឡែកទាំងកូនទាំងប្រពន្ធ បានទៅដល់ខ្នងលើគេអាកន្ទែងស្រះគេដាក់ថ្មដែកភ្លើងគេណា ដល់នេះពុស្សូសម្លេងគ្រាប់កាំភ្លើងប៉ាវ៉ាគេមកជួយ ដល់គេមកជួយទៅគេចូលមកវ៉ៃបំបែក ។

ផល្លា៖ ប៉ាវ៉ាណ្ហើងប៉ុន្មាននាក់ដែរ ប៉ុន្មានក្រុមប៉ុន្មានអីពូ?

សាវឿន៖ តែ១២នាក់ប៉ុណ្ណោះ ។

ផល្លា៖ តែ១២នាក់ទេ?

ប្រពន្ធ៖ បានគេមកជួយវាយបំបែកកុំអីងាប់ប្រជាជនអស់ ពួកខ្ញុំគេដាក់មួយឡែកអត់មានប្តីអ្នកអត់ មានប្តីនៅប្រហែល៥០គ្រួសារ ដែលប្តីៗចូលទៅធ្វើការខាងប៉ាវ៉ា ។

សាវឿន៖ ខ្ញុំដល់ឆ្នាំ៧៧ខ្ញុំចូលមកកូនរកប្រពន្ធ រកម៉ែវាគេជម្លៀស គេជម្លៀសម៉ែវត់ឲ្យតែផុតពីពួកខ្មែរក្រហមសម្លាប់ណា! ដើររកប្រពន្ធមិនឃើញមកឃើញនៅបន្ទាយឆ្មា ។

ប្រពន្ធ៖ ពួននៅថ្មពួកមួយខែៗខ្ញុំមិនដែលហ៊ានចេញពីផ្ទះទេ ម៉ែឪដាំបាយហើយយកទៅឲ្យហូបទៅគេដើរស៊ើបអ្នកណាប្តីមិននៅគេយកទៅវ៉ៃចោល ។

សាវឿន៖ តែចេញវ៉ៃគេស្ទួកងអាណា តែកងអាវឿនអត់មានថយសោះតែកងខ្ញុំទេ នេះពួកអាខ្មែរក្រហមនេះខ្ញុំវ៉ៃខ្លាំង កាលនៅប៉ាវ៉ាខ្ញុំវ៉ៃខ្លាំងដែរ ។

ប្រពន្ធ៖ ថាឲ្យតែនឹកឃើញចាស់ប៉ុននេះហើយមិនភ្លេចទេ ។

ប៊ុនថន៖ ពូនៅមេបញ្ជាការពូពីណាវិញពូ?

សាវឿន៖ បាទ!

ផល្លា៖ ខាងប៉ាវ៉ាមេបញ្ជាការពូ?

សាវឿន៖ តាលួត! គាត់ងាប់ហើយ

ផល្លា៖ ចុះគុយ ស៊ូតួនាទីគាត់អីគេកាលណ្ហើង?

សាវឿន៖ គាត់វរៈសេនាតូច ។

ផល្លា៖ វរៈសេនាតូច?

សារឿនៈ បាទ!

ប្រពន្ធៈ ទេមិនមែនទេវរៈសេនាធំតើ!

សារឿនៈ វរៈសេនាតូចកាលនៅក្នុងព្រៃ ។

ប្រពន្ធៈ គាហ្វូតណ្ហឹង?

សារឿនៈ អាយ្ហូតវរៈសេនាកងធំ បើគុយ ដាទេបានគាត់ធំ ។

ប្រពន្ធៈ អ៊ើគុយ ឈា ។

ផល្លាៈ គុយ ឈាណ្ហឹងវរៈសេនាធំដែលអត់ទេ?

សារឿនៈ បាទ! គាត់វរៈសេនាធំ គាត់វរៈតំបន់ណ៎ាក្លួយតាមរ៉ុង ។

ផល្លាៈ ចុះហ្វូតចឹងគាត់តួនាទីអីវិញចឹង?

សារឿនៈ វរៈសេនាធំ គាត់កាន់កងធំណ៎ា ។

ផល្លាៈ កាន់កងធំ?

សារឿនៈ បាទ!

ផល្លាៈ នៅប៉ារ៉ាមែន?

សារឿនៈ នៅប៉ារ៉ា ។

ផល្លាៈ ចឹងប៉ារ៉ាគេបង្កើតឡើងនៅឆ្នាំប៉ុន្មាន? កងប៉ារ៉ាណ្ហឹង?

សារឿនៈ គេបង្កើតតាំងពីឆ្នាំ៦៨ណោះ តាំងពីសម័យនៅតស៊ូនៅភ្នំបាញ់ចាប យើងណ្ហឹងទាហានពួក
គេណ្ហឹងឯងឲ្យតែគ្រប់អាយុគេយកទៅភ្នំបាញ់ចាប ម៉ាចូលខ្មែរសេរីណ្ហឹង ។

ប៊ុនថនៈ បាទ!

ផល្លាៈ ចឹងចូលខ្មែរក្រហមផ្សេងចូលប៉ារ៉ាផ្សេង ពូប្រាប់ខ្ញុំមេញថាធ្លាប់ចូលខ្មែរក្រហមនៅភ្នំបាញ់
ចាបណ្ហឹងដែរ?

សារឿនៈ បាទ! ខ្មែរក្រហមខ្ញុំ......

ប្រពន្ធៈ ខ្មែរក្រហមណ្ហឹងវាំនេះទេ..

សារឿនៈ ដែលខ្ញុំថា១៧មេសាដែលហ៊ុនសែនយកកងទ័ពមករំដោះណ្ហឹងខ្ញុំក៏រត់ចូលប៉ារ៉ា
ព្រោះគេដេញ បាញ់ព្រោះខ្ញុំប្រជាជនណ៎ា ។

ផល្លាៈ ចា៎!

សារឿនៈ កាលខ្មែរក្រហមក៏ខ្ញុំតស៊ូ ប៉ារ៉ាក៏ខ្ញុំតស៊ូ ។

ផល្លាៈ ចា៎!

ប្រពន្ធ: នៅមិនបាន ។

សារឿន: នៅមិនបាននាងព្រោះគេដេញបាញ់ វិសនឹងស្លាប់វាឲ្យស្លាប់ ។

ប្រពន្ធ: នេះណ្ហឹងស្លាប់ប្តីនៅប្រពន្ធរហេមរហាមវេទនា ។

សារឿន: ឯងចេញផុតវេទនាអារឿងប្រពន្ធរឿងកូនណ្ហឹង មិនថាខ្ញុំមិនថាកូនឯងតែគេដេញបាញ់ ហើយមិនរត់បំរាស់ បំរាស់រាងខ្លួននាង ហើយដូចសម្តេចហ៊ុនសែនចឹងបើគេកុំដេញបាញ់ទៅ គាត់មិនបានបំរាស់កងទ័ពទៅស្រុកយួនទេ ដូចតែគ្នាចឹងឯង ។

ផល្លា: ហើយពូមានដែលឃើញហ៊ុនសែនឃើញអីអត់ទេចឹង?

សារឿន: ពីជំនាន់សង្គ្រាមជួបគ្នាកាល៧០,៧១ ។

ផល្លា: ធ្លាប់ធ្វើជាមួយគ្នាមែនពូ?

សារឿន: គាត់ខាងនយោបាយ ហើយបែកគ្នាកាលពីយើងចុះពីស្រុកយួនម៉ោវៃស្រុកខ្មែរណ្ហឹងឆ្នាំ៧០ ទេណាំ យើងបែកគ្នាត្រឹមនោះឯង ។

ផល្លា: ចាំ!

ប៊ុនថន: ពូចូលបដិវត្តន៍នៅឆ្នាំណា?

សារឿន: ហាស៎?

ប៊ុថន: ខ្ញុំចូលបដិវត្តន៍នៅឆ្នាំ៧០ ។

ប៊ុនថន: ចូលដំបូងនៅណាវិញពូ?

សារឿន: ចូលដំបូងនៅភ្នំចាប ខេត្តបាត់ដំបងយើងណ្ហឹង ។

ប៊ុនថន: នៅក្នុងស្រុកអីវិញ?

សារឿន: មិនដឹងស្រុកអីទេ ដឹងតែខេត្តបាត់ដំបង ភ្នំបាញ់ចាប ពីដើមបែបគេហៅស្រុកបាត់ដំបង ។

ប៊ុនថន: ចូលជាមួយពីណាដំបូង?

សារឿន: គេចាប់យកទៅតែម្តង ។

ផល្លា: អ៎!

ប្រពន្ធ: ខាងនេះគេមានស្ម័គ្រណាគេចាប់បញ្ចូលតើ ។

ប៊ុនថន: នៅជាមួយពីណាដំបូង?

សារឿន: នៅជាមួយដំបូងនៅជាមួយកែវ មុន្នី ។

ប៊ុនថន: កែវ មុន្នី?

សារឿនៈ បាទ! លោកតាកែវ មុន្នី ។

ប៊ុនថនៈ ឈ្មោះគាត់ពេញឈ្មោះអី?

សារឿនៈ កែវ មុន្នីណ្ហឹង?

ប៊ុនថនៈ កែវ មុន្នីចឹងហ្នង?

សារឿនៈ បាទ! តែមិនដឹងត្រកូលគាត់ឈ្មោះអីខ្ញុំភ្លេចទៅ ដឹងតែគេហៅលោកតាកែវ មុន្នីៗ ។

ប៊ុនថនៈ គាត់អីស្សរៈមែន?

សារឿនៈ អីស្សរៈជាមួយលោកកៅ តក់ ។

ប៊ុនថនៈ លោកកៅតក់ ដក់ ធូនអីណ្ហឹង?

សារឿនៈ បាទ! ប៉ុន្តែគាត់ខ្ញុំបានដឹងប្រវត្តទេ ដែលខ្ញុំចូលទៅជួបជាមួយលោកតាកែវមុន្នីតែម្តង ។

ប៊ុនថនៈ ពូនៅជាមួយគាត់បានយូទេពូ?

សារឿនៈ បានយូ បានពីរឆ្នាំទៅរៀនជុំគ្នាទាំងអស់ ។

ប៊ុនថនៈ ទៅរៀននៅណាពូ?

សារឿនៈ ទៅរៀននៅហាណូយខាងជើង ។

ប៊ុនថនៈ ទៅរៀនហាណូយ? ពូបានទៅរៀននៅហាណូយដែរ?

សារឿនៈ បាទ! ចេញមកវិញនៅឆ្នាំ៧០,៧២បានវ៉ៃភ្នំបាតយើង ។

ប៊ុនថនៈ បាទ! ពូទៅរៀនហាណូយច្រើនទេពូ?

សារឿនៈ ៣០០នាក់ជាង ។

ប៊ុនថនៈ ៣០០នាក់?

សារឿនៈ ព្រោះវាសុទ្ធតែបានមេៗរៀនខ្លួន ។

ប៊ុនថនៈ បាទ!

សារឿនៈ ប៉ុន្តែមេណ្ហឹងមេជាមួយយួន យួនមួយក្រុមពួកយើងមួយក្រុម ។

ប៊ុនថនៈ ចុះទៅជាមួយកែវ មុន្នីណ្ហឹងមានពីណាទៀតទេ មេៗពូណ្ហឹង?

សារឿនៈ ខ្ញុំភ្លេចអស់ហើយ វាយូណាស់ហើយ ។

ប៊ុនថនៈ បាទ!

សារឿនៈ វាចូល៣០ឆ្នាំជាងហើយ មកដល់សព្វថ្ងៃបើគិតទៅវាចូល៥០ឆ្នាំហើយ ។

ប៊ុនថនៈ ពូទៅនៅណ្ហឹងមានស្គាល់ពីណាទៀតទេ ទៅរៀននៅហាណូយណ្ហឹង?

សារឿនៈ វាភ្លេចអស់ហើយ វាស្គាល់តែមេចាស់ៗ ។

ប៊ុនថន៖ ស្គាល់តែមេចាស់ៗណ្នឹងទេពូ?

សាវឿន៖ បាទ!

ផល្លា៖ ពីណាខ្លះមេចាស់ៗណ្នឹងលោកពូ?

សាវឿន៖ ពួកតាភឿន តាណៃ តារ៉េន តាញឹមយើង រស់ញឹមណ្នឹង!

ប៊ុនថន៖ តាញឹមណ្នឹងទៅដែរ?

សាវឿន៖ បាទទៅទាំងអស់ណ្នឹង ។

ប៊ុនថន៖ ទៅដំណាលពូដែរ?

សាវឿន៖ បាទ! ប៉ុន្តែគាត់មេពួកយើងកូន ។

ប៊ុនថន៖ ចុះខាងវៀតណាមពូមានស្គាល់ពីណាទេពូ?

សាវឿន៖ វៀតណាមអត់ស្គាល់ទេ ភ្លេចឈ្មោះអស់ហើយ ។

ប៊ុនថន៖ រៀនណ្នឹងរៀនជាមួយវៀតណាមមែនពូ?

សាវឿន៖ បាទរៀនជាមួយវៀតណាម ។

ផល្លា៖ រៀនណ្នឹងរៀនអីខ្លះ?

សាវឿន៖ រៀនខាងបច្ចេកទេសវ៉ៃ ។

ផល្លា៖ វ៉ៃបាញ់អីណ្នឹងពូ?

សាវឿន៖ បាទវ៉ៃនឹងបាញ់ រៀនផ្នែកនយោបាយរៀនតែបីខែប៉ុណ្ណោះ ។

ប៊ុនថន៖ រៀនជាមួយគ្រូវៀតណាមមែនពូ?

សាវឿន៖ បាទ! គ្រូវៀតណាមគេអ្នកបង្ហាត់ ។

ប៊ុនថន៖ បាទ! គេចេះខ្មែរដែរពូ?

សាវឿន៖ ចេះ! គេចេះនិយាយភាសាខ្មែរ ។

ប៊ុនថន៖ គេនិយាយច្បាស់ទេ?

សាវឿន៖ ច្បាស់!

ប៊ុនថន៖ ពូចាំឈ្មោះគាត់ទេ?

សាវឿន៖ មិនចាំទេវាយូណាស់ហើយ តាំងពីខ្ញុំនៅកម្លោះម្លេះ ។

ប៊ុនថន៖ ទៅនៅហាណូយ?

សាវឿន៖ បាទ!

ប៊ុនថន៖ ហើយពូចុះម៉ោវិញណ្នឹង មួយក្រុមពូមាន៣០០នាក់ណ្នឹងទាំងអស់គ្នាពូ?

សារឿនៈ បាទទាំងអស់គ្នាចុះមករៀបចំកងទ័ពនៅព្រៃស្អាត ។

ប៊ុនថនៈ ព្រៃស្អាត?

សារឿនៈ បាទ!

ប៊ុនថនៈ ពីណាចុះម៉ោ?

សារឿនៈ សម្តេចតាយើង!

ប៊ុនថនៈ សម្តេចតា? ម៉ោដំបូងពូម៉ោតែមួយក្រុមខ្មែរ៣០០នាក់ណ្ហឹងទេមានខាងវៀតណាមម៉ោជាមួយទេ?

សារឿនៈ ម៉ោ៦០០នាក់ទៀត ។

ប៊ុនថនៈ ប៉ុន្តែ៦០០នាក់ណ្ហឹងមិនមែនជាកងទ័ពទេ?

សារឿនៈ កងទ័ពទាំងអស់ ។

ប៊ុនថនៈ ជាកងទ័ព?

សារឿនៈ បាទកងទ័ពទាំងអស់ ។

ប៊ុនថនៈ នៅពេលម៉ោដល់ណ្ហឹងគេបែងចែកទៀត?

សារឿនៈ គេបែងចែកបំបែកគ្នា ដូចថាអាអូនឯងចឹងទៅជាមួយបង១កាន់មួយក្រុមទៅពួកវៀតណាមកាន់វៀតណាម១២នាក់ទៅនៅជុំគ្នានៅភូមិខ្ញុំ ដល់នាងវៀតណាម១២នាក់ខ្មែរ១២នាក់ ។ បំបែកគ្នានៅឧទាហរណ៍ថាអូនឯងទៅទិសនៅខាងណា នៅស្រុកថ្មពួកចេះអូនឯងទៅគ្នា១២នាក់ខ្មែរ១២នាក់ខ្ញុំ១២នាក់ បើថានាងទិសខាងណាទិសខាងស្វាយស៊ីសុផុននាងខ្មែរ១២នាក់យួន១២នាក់ ។

ផល្លាៈ ចុះពីណាគ្រប់គ្រងពូខ្មែរ១២វៀតណាម១២នាក់ណ្ហឹង?

សារឿនៈ ទេ! ឧទាហរណ៍ថានាងឯងប្រធានក្រុមនាងឯងជាមេគ្រប់គ្រង ហើយវៀតណាមគេវៀតណាមគ្នាគេ ។

ប៊ុនថនៈ មេរបស់វៀតណាមមួយ?

សារឿនៈ បាទ!

ប៊ុនថនៈ នៅជាមួយគ្នា?

សារឿនៈ ក្នុងពីក្រុមនោះក្នុង២៤នាក់នោះវាមានពេទ្យបីខាងវៀតណាមណ៎?

ប៊ុនថនៈ បាទ!

សារឿនៈ ពេទ្យវៀតណាមពីរពេទ្យខ្មែរមួយ ។

ប៊ុនថន៖ បាទ! ពេទ្យវៀតណាម?

សាវឿន៖ បាទ!

ប៊ុនថន៖ ចុះមានបែងចែកផ្នែកសេដ្ឋកិច្ច ផ្នែកនយោបាយអីនៅក្នុងកងណ្ហឹងទេ?

សាវឿន៖ មាន!

ប៊ុនថន៖ មានបែងចែកដែរ?

សាវឿន៖ មានបែងចែក អាមួយនៅខាងផ្នែកសេដ្ឋកិច្ចនៅខាងផ្នែកនយោបាយ ខាងទស្សនៈអប់រំគេ ថារណៈសេរ្សីរួបរួមជាតិណា៎?

ប៊ុនថន៖ បាទ!

សាវឿន៖ ខាងវៀតណាមពីរខាងខ្មែរក៏ពីរចែកគ្នាដើរអប់រំនៅតាមភូមិ ។

ប៊ុនថន៖ បាទ! អញ្ចឹងពូមកដល់ដំបូងមកដល់ភូមិអីពូនិយាយម៉េញណ្ហឹង?

សាវឿន៖ ពូមិនស្គាល់ទេភ្លេចឈ្មោះអស់ហើយ ។

ប៊ុនថន៖ ចឹងខេត្តណាពូ?

សាវឿន៖ គេហៅថាព្រៃៗស្អាត!

ប៊ុនថន៖ ព្រៃស្អាត?

សាវឿន៖ បាទ! ព្រៃស្អាក ។

ប៊ុនថន៖ ព្រៃស្អាក?

សាវឿន៖ បាទ!

ប៊ុនថន៖ ប្រហែលជាខេត្តមានជ័យឬបន្ទាយមានជ័យ?

សាវឿន៖ ទេចុះពីព្រៃយើងនេះទៅ ចុះពីភ្នំដងរែកនេះទៅ ។

ប៊ុនថន៖ បាទ! ព្រៃស្អាក ។

សាវឿន៖ បាទ! ព្រៃធំណាស់ ។

ប៊ុនថន៖ ចុះតាញឹម តាកែវ មុន្នីអីគាត់នៅខាងណាវិញ?

សាវឿន៖ គាត់នៅមួយប៉ែកខាងផ្នែកគាត់ផ្សេង ។

ប៊ុនថន៖ គាត់នៅខាងណា?

សាវឿន៖ គាត់រស់នៅទីនោះឯង តែគាត់នៅខាងផ្នែកសម្តេចតា ។

ប៊ុនថន៖ ហើយពូបែកមួយក្រុមទៅ?

សាវឿន៖ បាទ! ខ្ញុំមួយក្រុមប្អូនឯងមួយក្រុមទៅ ។

ប៉ុនថន៖　ពូគ្រប់គ្រង ពូមានបានគ្រប់គ្រងទេ?

សាវឿន៖　គ្រប់គ្រង១២នាក់ ។

ប៉ុនថន៖　១២នាក់?

សាវឿន៖　ប្អូនឯងចឹង កាន់យូនទៅ១២នាក់ ប៉ុន្តែដល់ពេលបាយៗជុំគ្នាទៅទាំងយួនទាំងខ្មែរ ។

ប៉ុនថន៖　បាទ!

ប្រពន្ធ៖　អានេះសម្ភាសន៍យកទៅធ្វើអី?

ផល្លា៖　អត់ទេ! គ្រាន់តែទុកជាឯកសារណ្ហឹង ។

ប្រពន្ធ៖　អ៊ំ!

សាវឿន៖　អានេះអត់កើតគេបញ្ជូនមករកតែខ្ញុំ ប្រធានភូមិ ។

ប៉ុនថន៖　បាទ!គាត់ឲ្យមកសាកសួរព្រោះពូដឹងច្រើន ។

សាវឿន៖　បាទ!

ប៉ុនថន៖　អញ្ចឹងពូកាលណ្ហឹងពូដូចដឹងនិងស្គាល់ចិត្តស្និទ្ធ ស្គាល់ច្បាស់អីចឹងមេតាញឹមអី?

សាវឿន៖　ស្គាល់ច្បាស់!

ប៉ុនថន៖　ធ្លាប់និយាយជាមួយគ្នាទេ?

សាវឿន៖　នៅជុំគ្នា ទើបតែបែកគ្នានៅឆ្នាំ៧៩នេះណ្ហឹង គាត់ធ្វើចៅហ្វាយខេត្តខ្ញុំធ្វើកងទ័ពទៅ ។

ប៉ុនថន៖　កាលណ្ហឹងគាត់អាយុប៉ុន្មានដែរពូមានដឹងទេ?

សាវឿន៖　មិនដឹងទេ! អាយុគាត់ច្រើនណាស់ ។

ប៉ុនថន៖　បងពូទៀត?

សាវឿន៖　អ៊ូមិនមែនត្រឹមតែបងខ្ញុំទេ បងឪខ្ញុំទៀតណ៎ា គាហើយ មើលគាត់ស្លាប់អាយុគាត់យ៉ាងតិច ៧០ ។

ប៉ុនថន៖　បាទ!

សាវឿន៖　តែគេសម្លាប់គាត់ គាត់មានធ្វើការអីកើត គាត់មេគណៈបក្ស ។

ប៉ុនថន៖　អញ្ចឹងចេញពី នៅកងនៅវៀតណាម៣០០នាក់ណ្ហឹងក្រៅពីទៅខាងខេត្តបាត់ដំបងណ្ហឹងមានខេត្តណាទៅជាមួយទៀតទេ?

សាវឿន៖　មាន! បើយើងឧទាហរណ៍ថាយើងរំដោះថ្មពួកបានចឹង គេអួតខាងឃោសនាចឹងទៅណ៎ាអូន!

ប៉ុនថន៖　បាទ!

សារឿនៈ ជាមួយនាងចឹងទៅដូចថាឃោសនាគ្រូសារខ្ញុំ បងអើយសង្គ្រាមវាធ្ងើចេះ សង្គមវាប្រែប្រួល ចេះមួយចុះមួយទៅណា៎ ។

ប៊ុនថនៈ បាទ!

សារឿនៈ អាណ្ហឹងផ្នែកនយោបាយណា៎!

ប៊ុនថនៈ បាទ!

សារឿនៈ ដល់ពេលណ្ហឹងមីនាងក៏មានអូនឯងក៏មានហៅថាមានចិត្តណា៎ នឹកឃើញដល់សម្ដេចតាយើង អាណ្ហឹងនឹកឃើញដល់សម្ដេចមិនមែនចង់បានរូមទេណា៎ ពួកកូនឯងក៏ដាក់ចិត្តវាកម៉ោណ្ហឹង ហ្នឹង ។ ហើយឥលូវមានដូចថាអាអូឯងចូលម៉ោសុំអង្ករ វ័យអង្ករប្រជាជនទុកឲ្យកងទ័ពហូប នាងឯងចូលម៉ោវ័យពីយាយនេះបានអង្ករទុកឲ្យកងទ័ពហូប អាណ្ហឹងគេថាឃោសនាអប់រំ អញ្ចឹងបានក្នុងឯកសារកំម្មុយនីសគេថារណៈស្សេរ្សបរួមជាតិកម្ពុជា ឃោសនាអប់រំមាត្រាទី ១២ ជំពូកទី៣ ។

ប៊ុនថនៈ បាទ!

សារឿនៈ អាជំពូកទី៣ណ្ហឹងអាខាងឃោសនាណ្ហឹងឯង! ប្អូនឯងប្រើនយោបាយចេះមួយចុះមួយប្រាប់ ប្រជាជនទៅប្រជាជនមានបាក់ទឹកចិត្តទៅលើអាអូនឯង ។

ប៊ុនថនៈ បាទ!

សារឿនៈ ហេតុដូច្នេះហើយកងទ័ព១២ឬក៏២០នាក់៣០នាក់ចូលមកភូមិបន្ទាយឆ្មា អូនឯងនាំកងទ័ព ចូលភូមិបន្ទាយឆ្មាអូនឯងអាចលាក់បាន តែបើកងទ័ពលន់ នល់ អូនឯងលាក់អត់បានទេ ទាល់តែអាអូនឯងនយោបាយខ្លាំងជាងសម័យលន់ នល់ ។

ប៊ុនថនៈ បាទ!

សារឿនៈ ខាងឃោសនា កាលនោះនយោបាយខ្លាំងជាង ។

ប៊ុនថនៈ ជ្រៅជាងពូ?

សារឿនៈ បាទ! គេជ្រៅជាង!

ប៊ុនថនៈ បាទ! ចុះពូបំបែកក្រោយម៉ោទៅកាន់ខាងស្រុកណា?

សារឿនៈ កាន់តែកងទ័ពណ្ហឹង មើលតែកងទ័ពណ្ហឹងអត់មានបានកាន់ស្រុកណាទេ ។

ប៊ុនថនៈ និយាយថាចេញទៅបោះទីតាំងនៅណា?

សារឿនៈ គ្រាន់តែចេញម៉ោមុនដំបូងបោះទីតាំងនៅហៅថាភូមិឈូកៗយើង ខេត្តសៀមរាប ។

ប៊ុនថនៈ បាទ!

សារឿនៈ ខេត្តសៀមរាប ប៉ុន្តែស្រុកស្រីស្នំ ។

ប៊ុនថនៈ បាទស្រុកស្រីស្នំ!

សារឿនៈ ដល់បោះទីតាំងនៅនោះបានមួយឆ្នាំ ដល់ឆ្នាំ៧២, ៧៣ឡើងបានដកទីតាំងពីស្រីស្នំម៉ោមក បោះជំរុំខិតមកមុខបន្តិចទៀត ។

ប៊ុនថនៈ មេ៥២មានទម្លាក់ដល់ណ្ហឹងទេពូ.?

សារឿនៈ បាទទម្លាក់ដល់ណ្ហឹងឯង! មិនធម្មតាទេ អានេះនិយាយពីប្រវត្តណាអូន!

ប៊ុនថនៈ បាទ! មានស្លាប់មានអីទេពូ?

សារឿនៈ មានអូន! មានកង៏ទ័ពខ្មែរក្រហមគឺស្លាប់ភាគច្រើនណាស់ ប៉ុន្តែអ្នកដែលគេតស៊ូគេនៅតែតស៊ូ ។

ប៊ុនថនៈ បាទ!

សារឿនៈ គេថាខ្មែរយើងតស៊ូស្វិតណាស់ មិនមែនផុយទេខ្មែរយើងតស៊ូស្វិតណាស់ ។

ប៊ុនថនៈ អញ្ចឹងកងពូណ្ហឹងមានអ្នកណាគ្រប់គ្រងពីលើទៀតទេ? មានបំបែកទៅជាវរៈជាអីទេ?

សារឿនៈ មាន! បំបែកជាវរៈមានលោកម៉ៅ ។

ប៊ុនថនៈ ស្អីម៉ៅ?

សារឿនៈ មិនដឹងស្អីម៉ៅទេ ភ្លេចបាត់ហើយ អាណ្ហឹងនិយាយពីប្រវត្តិតស៊ូច្រើនណាស់អូន ។

ប៊ុនថនៈ ម៉ៅកាលណ្ហឹងគាត់កាន់ខាង..?

សារឿនៈ វរៈសេនាតូច!

ប៊ុនថនៈ វរៈសេនាតូច?

សារឿនៈ បាទ!

ប៊ុនថនៈ ចុះនៅក្នុងកងវរៈសេនាធំវិញ?

សារឿនៈ កងវរៈសេនាធំឈ្មោះលោកធី!

ប៊ុនថនៈ លោកធី?

សារឿនៈ បាទលេខ២៣!

ប៊ុនថនៈ លេខ២៣?

សារឿនៈ បាទលេខ២៣ បើវរៈសេនាតូចលេខ១២ កាលណ្ហឹងគេនិយាយថាវរៈសេនាតូចវរៈសេនាធំ កាលនៅក្នុងព្រៃអត់មានអ្នកណាគោរពអ្នកណាទេ ។

ប៊ុនថន: ម៉េចអញ្ចឹង?

សារឿន: អត់មានអ្នកណាគោរពអ្នកណាទេ! ឧទាហរណ៍ថាអូនឯងកាន់វរៈសេនាធំអូនឯងខុសខ្ញុំមានសិទ្ធបាញ់ចោល ។

ប៊ុនថន: បាទ!

សារឿន: ព្រោះខុសច្បាប់! អត់មានអ្នកណាត្រង់អ្នកណាទេ!

ប៊ុនថន: ចុះពេលបញ្ហាអីចឹង?

សារឿន: ពេលបញ្ហាយើងគោរពមេ! តែចេញផុតពីកន្លែងហ្នឹងអត់មានអ្នកណាគោរពអ្នកណាទេ! អត់មានមេមានកូនអីទេគឺគោរពរៀងខ្លួនតែម្តង ។

ប៊ុនថន: គោរពយ៉ាងម៉េចពូ?

សារឿន: ដូចថាអូនឯងគោរពសិទ្ធអូនឯងចឹងទៅ ឧទាហរណ៍ថាអូនឯងជាបញ្ជាការកងធំ ខ្ញុំជាបញ្ជាការកងតូចអូនឯងគោរពខ្ញុំ ខ្ញុំគោរពអូនឯង អត់មានអាញៀអាញៀទេ ។

ប៊ុនថន: ទាល់តែនៅក្នុងសមរភូមិបានបញ្ជា?

សារឿន: បានបញ្ជា!

ប៊ុនថន: បាទ!

សារឿន: ឧទាហរណ៍ថាអូនឯងកាន់វរៈសេនាធំមាន១៣០នាក់អូនឯងបញ្ជាបានតែកូនចៅអូនឯងទេ វាកាន់បក្សគ្នាចឹង មេតាមមេ កូនតាមកូន ។

ប៊ុនថន: អញ្ចឹងលោកពូនៅជាមួយឈ្មោះម៉ៅណ្នឹងរហូតឬក៏ចូលទៅផ្សេងទៀតលោកពូ?

សារឿន: ម៉ៅណ្នឹង?

ប៊ុនថន: បាទ!

សារឿន: ដូរផ្សេងទៀតនៅឆ្នាំ៧៥ បែកគ្នាត្រឹមណ្នឹង ។

ប៊ុនថន: បែកគ្នា?

សារឿន: បាទ!

ប៊ុនថន: ពូគាត់នៅក្នុងកងណ្នឹងរហូតមែនពូ?

សារឿន: គាត់ឡើងមកកាន់កងពលកាន់អី ។

ផល្លា: អញ្ចឹងពូថាពូកាន់វរៈតូចដែរឬអត់ទេ?

សារឿន: បាទ!

ផល្លា: ពូកាន់វរៈសេនាតូចដែរពូណោះ!

សារឿនៈ បាទ!

ប៊ុនថនៈ ចុះពូឡើងម៉ោផុតពីស្រុកស្រីស្នំណ្ហឹងពូមានទៅណាទៀតទេ?

សារឿនៈ ទេមិនទៅណាទេ!

ប៊ុនថនៈ អានេះនិយាយអាវៃជិតបែកណា៎ ជិតបែកពូចូលម៉ោ?

សារឿនៈ បាទចូលម៉ោបាត់ដំបង!

ប៊ុនថនៈ កាលណ្ហឹងកងពលលេខប៉ុន្មាន?

សារឿនៈ កងពលលេខ២០៦ ។

ប៊ុនថនៈ វៃកៀកម៉ោជិតបាត់ដំបងនេះ?

សារឿនៈ បាទវៃកៀកបាត់ដំបង ។

ប៊ុនថនៈ ចូលមកដល់ភ្នំមកគេរៀបចំយ៉ាងម៉េចកងទ័ព?

សារឿនៈ ទេចូលម៉ោគេរៀបចំហើយស្រេច ចូលមកតាមដំណើរ កាន់ទាហានទៅដូចថាអូនឯងកាន់មួយកងចឹងទៅនៅភូមិបន្ទាយឆ្មា ហើយបងកាន់ទាហាននៅភូមិផ្សេងទៅ ។

ប៊ុនថនៈ បាទ!

សារឿនៈ ដល់ពេលឆ្នាំ៧៦,៧៧វាមានបញ្ហាកើតឡើងហើយ ។

ប៊ុនថនៈ ចឹងពូនៅដដែល ពូនៅកងដដែល?

សារឿនៈ ខ្ញុំរត់ចេញ!

ប៊ុនថនៈ និយាយពេលគេបែកឆ្នាំ៧៩ភ្នំ?

សារឿនៈ នៅតែដដែលៗ!

ប៊ុនថនៈ បាទ!

សារឿនៈ កាន់វរៈសេនាតូចនៅវរៈសេនាតូចដដែល ។

ប៊ុនថនៈ បាទ!

សារឿនៈ ខ្ញុំបានម៉ែវារួចនៅឆ្នាំ៧៩!

ប៊ុនថនៈ កាលណ្ហឹងគេរៀបចំឲ្យមែន?

ប្រពន្ធៈ ខ្ញុំគេរៀបចំឲ្យ!

សារឿនៈ ដល់ពេលខ្ញុំការរួចគេបញ្ជូនខ្ញុំឲ្យទៅនៅព្រំដែន ដល់ពេលបានប៉ុន្មានបានប្រហែលទម្ងន់កូនមួយគេចោទថាខ្ញុំណ្ហឹងក្រុមក្បត់ ។

ប៊ុនថនៈ បាទ!

សារឿនៈ គេឲ្យបញ្ជូនយកទៅសម្លាប់ ។

ប៊ុនថនៈ បាទ!

សារឿនៈ មួយសាណ្ហឹងបានប្រពន្ធកូនគេអត់ដឹងទេ ទាល់តែខ្ញុំបានកូនពីបានប្រពន្ធដឹងថាគេយកខ្ញុំទៅសម្លាប់ ។

ប៊ុនថនៈ អញ្ចឹងកាលណ្ហឹងពីណាគ្រប់គ្រងពេលបែកភ្លាម គេរៀបចំជាគណៈភូមិភាគ គណៈតំបន់ កាលណ្ហឹងនៅបាត់ដំបងពីណាគ្រប់គ្រង?

សារឿនៈ តារស់ ញ៉ឹម ដែលខ្ញុំថាណ្ហឹង!

ប៊ុនថនៈ រស់ ញ៉ឹម!

សារឿនៈ បើគណៈកងពលធំគេសម្លាប់ចោលបាត់ហើយ ស្លាប់អស់ហើយចាស់ៗរត់វាមិនរួច ។

ប៊ុនថនៈ អញ្ចឹងគេបញ្ជូនពូទៅព្រំដែនណ្ហឹងទៅខាងណាវិញពូ?

សារឿនៈ នេះភ្នំដងរែកយើងនេះ!

ប៊ុនថនៈ ភ្នំដងរែក!

សារឿនៈ អាណ្ហឹងជាប់ព្រំដែនថៃណ្ហឹង ។

ប៊ុនថនៈ បាទព្រំដែនខ្មែរថៃ!

សារឿនៈ ទៅណ្ហឹងទៅដេកគ្មានទៅពិបាកការពារអី គ្មានអ្នកណាទៅចូលលុកលុយដូចសព្វថ្ងៃនេះអី ។

ប៊ុនថនៈ គេដាក់ទៅៗដើម្បីអីពូ?

សារឿនៈ ឲ្យនៅការពារព្រំដែន យាមកងទ័ពព្រំដែន ។

ប៊ុនថនៈ បាទ! ដកទៅណ្ហឹងមានដកអ្នកផ្សេងៗទៅទៀតទេ?

សារឿនៈ ដកច្រើនណាំ! មួយវរៈសេនាធំ!

ប៊ុនថនៈ ដកតែមេៗបញ្ជាការឬក៏ដកទាំងអស់?

សារឿនៈ ដកទាំងអស់កងទ័ព ដល់គេហៅមកវិញមកសម្លាប់ចោលសម្លាប់តែកងទ័ព សឹងតែផ្ដាច់ពូជណាំ! ដូចខ្ញុំនឹកដល់ទឹកដោះម្ដាយថ្ងៃ ទេវតាលោកជួយបានរស់ដល់សព្វថ្ងៃ ។

ប៊ុនថនៈ អញ្ចឹងដំបូងសមមិត្តស៊ូអីនៅបាត់ដំបងដែរមែនពូ ស៊ូហៅប៉ាន?

សារឿនៈ ស៊ូហៅប៉ានណ្ហឹង?

ប៊ុនថនៈ បាទ!

សារឿនៈ គាត់រស់នៅស្វាយចេកនេះឯង!

ប៊ុនថនៈ គាត់នៅស្វាយចេក?

សារឿនៈ បាទ!

ប៊ុនថនៈ គាត់តស៊ូទេពូ?

សារឿនៈ បាទតស៊ូ គាត់ចូលឆ្នាំ៧៤ ។

ប៊ុនថនៈ ៧៤?

សារឿនៈ បាទ!

ប៊ុនថនៈ ចូលក្រោយពូ?

សារឿនៈ បាទក្រោយ!

ប៊ុនថនៈ ស៊ូណ្អឹងគាត់នៅណា គាត់នៅខាងបាត់ដំបងដែរមែនពូ?

សារឿនៈ ស្រុកកំណើតគាត់នៅស្វាយចេកនេះហើយ ។

ប៊ុនថនៈ ស្វាយចេក?

សារឿនៈ បាទ!

ប៊ុនថនៈ ប៉ុន្តែគាត់ស្លាប់ដែរមែនពូ?

សារឿនៈ គាត់នៅតើសព្វថ្ងៃតែនៅខេត្តឧត្តមានជ័យ!

ប៊ុនថនៈ អញ្ចឹងបែកភ្លាម៧៥ណ្អឹងពូជួបទេចាស់ៗជំនាន់ពូទៅរៀននៅ...?

សារឿនៈ ជួប! ជួបខ្លះអត់ខ្លះ!

ប៊ុនថនៈ បានជួបច្រើនដែរពូ?

សារឿនៈ ទេជួបមិនច្រើនទេអូន វាស្លាប់ច្រើន វាស្លាប់អស់ម៉ាជំនាន់ពួកខ្ញុំនៅសល់ខ្ញុំនេះ បើអ្នកនៅរស់យ៉ាងច្រើន៥នាក់ បើម្នាក់ឈ្មោះមិត្តហុងៗសព្វថ្ងៃបានប្រពន្ធនៅស្វាយចេកវាកាំបុតជើងទាំងអស់ ។

ប៊ុនថនៈ ឈ្មោះអីហុង?

សារឿនៈ ហុង! នៅជុំគ្នាជាមួយខ្ញុំកាលពីដើម ឥលូវបាត់ជើងអស់ហើយ! វាភាគច្រើនរស់តិចណាស់ អូន ។

ប៊ុនថនៈ បាទ! មានជួបគាញឹមគាអីទេពេលបែកបាត់ដំបង?

សារឿនៈ ទេកាលពីគាត់គេមិនទាន់យកទៅសម្លាប់ជួបគ្នាដែរ!

ប៊ុនថនៈ បាទជួបគ្នាមុនបែក!

សារឿនៈ ពេលទៅរៀនទៅអីជួបជុំគ្នា ទៅរៀននៅកន្លែងគាត់ណ្អឹង ។

ប៊ុនថនៈ បាទ!

សារឿនៈ កាលណ្នឹងគាត់ហៅ គាត់បបួលទៅរៀន៦ថ្ងៃហៅមេៗទៅណា៎ ។

ប៊ុនថនៈ បាទ!

សារឿនៈ ច្រើនណាស់ជីវិតតស៊ូ និយាយប៉ុន្មានក៏មិនចប់ ។

ប៊ុនថនៈ ពូខ្ញុំចង់សួពូថាគេបញ្ជូនពូម៉ោព្រំដែនណ្នឹង និយាយថាគេចាប់ពូណ្នឹងគេដក....

សារឿនៈ គេមកចាប់ខ្ញុំនៅបន្ទាយឆ្មានេះឯង ។

ប្រពន្ធៈ ដែលនេះនោះ ដែលមកចាប់ណ្នឹងវាឈប់ហើយ ។

សារឿនៈ អាណ្នឹងគេចាប់ខ្ញុំយកទៅមុនដំបូង ដល់គេដេញចាប់ពិបាកនេះរត់ចូលប៉ាវ៉ាហ្មងទៅ ។

ប៊ុនថនៈ គេដកពូម៉ោពីព្រំដែនហើយបានពូចូលម៉ោបន្ទាយឆ្មា?

សារឿនៈ បាទដកចេញពីកន្ទែងកងទ័ព ដកចេញពីមេ ខ្ញុំមេណា៎ សួម៉ែវាមើលខ្ញុំមេណា៎!

ប៊ុនថនៈ មេវរៈសេនាធំមែនពូ?

សារឿនៈ វរៈសេនាតូច!

ប៊ុនថនៈ វរៈសេនាតូច?

សារឿនៈ វរៈសេនាធំប៉ុន្តែខ្ញុំរងគេ!

ប៊ុនថនៈ បាទ!

សារឿនៈ ដល់នេះគេដកខ្ញុំចេញ ដល់មកនៅបន្ទាយឆ្មានេះបានគេចូលមកដេញចាប់ខ្ញុំ ។

ប៊ុនថនៈ បាទ!

សារឿនៈ ដល់នេះខ្ញុំនៅមិនបានខ្ញុំរត់ទៅ..។

ប្រពន្ធៈ គេដកចេញនាង ដល់ពេលគេដកចេញមកនៅធ្វើស្រែ ដល់នេះនៅមិនបានគេចាប់ទៅ ។

ប៊ុនថនៈ គេដកចេញច្រើនទេពូ ក្រៅពីពូមានអ្នកផ្សេងៗទៀតទេពូ?

សារឿនៈ ទេ! ដកតែខ្ញុំមួយណ្នឹង!

ប៊ុនថនៈ ដកតែពូមួយ?

ប្រពន្ធៈ ដកតែគាត់មួយណ្នឹងឯង!

សារឿនៈ ដកតែខ្ញុំមួយ!

ប៊ុនថនៈ ដកណ្នឹងគេនិយាយម៉េចជាមួយពូដំបូង?

សារឿនៈ គេថាបងឯងចាស់ហើយ! បងឯងតស៊ូយូហើយបងឯងសម្រាកខ្លះទៅ ទៅនៅសហករណ៍ទៅ ។

ប៊ុនថនៈ បាទ! គេនិយាយចឹង?

សារឿនៈ  ដល់ខ្ញុំៗថាទេ ខ្ញុំតស៊ូស្លាប់ដើម្បីជាតិ ដើម្បីទឹកដី ដកខ្ញុំចេញខ្ញុំមិនទៅទេ!

ប៊ុនថនៈ  បាទ!

សារឿនៈ  ដល់នេះគេយកនារតីទៅ កងទ័ពនារតីទៅ ដល់ខ្ញុំមកនៅនេះមិនបានមួយខែផងគេចាប់ខ្ញុំ ។

ប៊ុនថនៈ  ខាងនារតីចូលម៉ោដូចថាអត់មានគម្រាមគំហែងអីពូទេពូ?

ប្រពន្ធៈ  ទេ! នារតីពួកយួនដេញម៉ោពីនោះ! ឪខ្ញុំក៏ងាប់ដោយសារស្នាដៃពួកនារតី ។

ប៊ុនថនៈ  បាទ!

ប្រពន្ធៈ  ឪមួយ, ប្អូនមួយ ឪខ្ញុំអត់បាននេះទេងាប់ប្អូន នែ៎គាត់នេះបងគាត់ប្រាប់ថាឃើញពូណ្ហឹងបាន ក្របីមួយ ទៅក៏នាំកូនទៅយក ដល់ទៅយកគេចាប់ប្អូនខ្ញុំ វាចាប់ឪខ្ញុំគិតទៅវាឲ្យនាំផ្លូវទៅភ្នំ ដងរែក ដល់បានប៉ុន្មានយប់បានគាត់មកសួរកកូន សួថាឃើញកូនខ្ញុំដល់ផ្ទះនៅ? ដល់ទៅ ឃើញខ្មោចកូននៅឯក្បាលក្របីវាសម្លាប់ចោល ឪខ្ញុំគាត់បានរស់ ។

សារឿនៈ  វាបាក់ទ័ពពីភូមិថ្មដាច់យើងនេះ ពួកខ្ញុំឡើងវិ៉ ។

ប្រពន្ធៈ  គ្រាន់តែរទេះរាប់រយរទេះនៅចោល! របស់របរ មាសប្រាក់គេចោលយ៉ាងច្រើននៅគរ វា រត់រកប្រាស់រៀងខ្លួន វាយកឪខ្ញុំធ្វើជាផ្លូវជូនវាទៅ ។ កាលខ្ញុំ១៦ឆ្នាំយួនចូលម៉ោហើយ យួនចូលម៉ោវាកៀខ្ញុំ វាចាប់ខ្ញុំតាំងពីខ្ញុំអាយុ១៦ឆ្នាំណោះ ថាយួនម៉ោហើយវាចាប់ ប្រជាជន វាដេញកៀរប្រជាជនទៅដល់អាភ្នំកំបូរណោះ ។

ប៊ុនថនៈ  ហើយលោកពូចាប់ម៉ោថ្ងពួកនេះបានប៉ុន្មានថ្ងៃបានគេបញ្ជូនពូទៅបាត់ដំបង?

សារឿនៈ  ដល់កកោះ!

ប៊ុនថនៈ  ដល់កកោះ?

សារឿនៈ  បាទ!

ប្រពន្ធៈ  ទៅទាំងខ្ញុំទាំងអីនេះឯង!

ប៊ុនថនៈ  បាទ!រហូតដល់កងទ័ពវៀតណាមចូលម៉ោមែនពូ?

សារឿនៈ  បាទ!

ប្រពន្ធៈ  កងទ័ពវៀតណាមចូលម៉ោវាកៀរយកពួកខ្ញុំនេះទៅចូលខាងភូមិវា ដល់នេះវាកៀរអ្នកស្រុក ទៅទាំងអស់ កៀរទៅអាភ្នំស្រាក្រាមណ្ហឹង ក្តួយឯងស្គាល់ទេ?

ប៊ុនថនៈ  ស្រាក្រាម!

សារឿនៈ  ស្រាក្រាមទ័ពសៀមយើងណ្ហឹង!

ប្រពន្ធៈ ទ័ពសៀមយើងណាំ វាកៀរចូលទៅអាភ្នំនោះ ដល់នោះគ្រាប់វាផ្ទោងៗប្រជាជនវាច្រើន វាប្រាស់យកវៀងខ្លួន វាទៅតែខ្លួនវា ប្រជាជនត្រលប់មកក្រោយវិញ ដល់ពេលត្រលប់មកពីភ្នំស្រាក្រោមវិញវាក៏នាំប្រជាជនគ្នាវារត់ទៅចូលទៅដល់ណាដល់ណី ប្រជាជនក៏នាំគ្នាត្រលប់មកវិញនាំគ្នាដដែកថាឃ្លានអង្ក ឃ្លានអី ឃ្លានស្ករឃ្លានអីវាចេះបងប្អូនអ្នកស្រុក ។

ប៊ុនថនៈ ក្រោយម៉ោនៅបន្ទាយឆ្នានេះពីណាអ្នកគ្រប់គ្រង?

ប្រពន្ធៈ ទេមកនៅ ប្រជាជនធម្មតាស្រុកកំណើត!

ប៊ុនថនៈ អត់ទេចង់និយាយថាពីណាអ្នកគ្រប់គ្រង ខាងប៉ុាវ៉ា ខាងខ្មែរក្រហម ឬក៏ខាងណា?

សាវឿនៈ ទេខាងប្រជាជនយើងណ្ហឹង!រ

ប្រពន្ធៈ អត់ដែលមានអ្នកណាគ្រប់គ្រងទេ នៅជុំគ្នាជាមួយប្រជាជនយើងទាំងអស់គ្នា ។

សាវឿនៈ ដល់៧៩មានអ្នកណាគ្រប់គ្រង!

ប៊ុនថនៈ បាទ! អញ្ចឹងតំបន់ណ្ហឹងចំរុះ?

សាវឿនៈ គ្មានអ្នកណាចាត់តាំងអីទេ! យួនក្បាប់តែប្រជាជនយើងអត់ទាន់មានអ្នកណាគ្រប់គ្រងទេ? អត់ទាន់មានប្រធានភូមិ មេឃុំអីទេ មិនទាន់បែងចែកទេ កងទ័ពវៀតណាមម៉ោគេមានជំនាញគេស្រាប់ ។

ប៊ុនថនៈ បាទ!

សាវឿនៈ ខាងកងទ័ពគេ ខាងយើងប្រជាជនយើងណ្ហឹងឯង ។

ប៊ុនថនៈ បាទ!

សាវឿនៈ គេមានបានចាត់តាំងថាបងនេះគឺប្រធានភូមិ បងនោះគឺប្រធានឃុំអីអត់ទេ!

ប៊ុនថនៈ ចុះខ្មែរក្រហមមានដែលចូលម៉ោទៀតទេ?

សាវឿនៈ ទេ! មិនដែលចូលទេ! វារត់ទៅបាត់ជ្រាប ។ មានតែអានារតីវារត់ម៉ោពីខាងត្បូង ហើយវាចោលរបស់របរ ហើយវាថាយួនដល់ហើយៗ ។

ប៊ុនថនៈ បាទ! ប៉ុាវ៉ាចូលម៉ោ!

ប្រពន្ធៈ នៅប៉ុាវ៉ាណ្ហឹងនៅដល់ពេលណាបានចេញពីប៉ុាវ៉ាវិញ?

សាវឿនៈ នៅទាល់តែយួនចេញពីខ្មែរបានប៉ុាវ៉ាចូលក្រោយ ខ្ញុំនឹកឃើញខ្មែរវៃខ្មែរ អញ្ចតស៊ូតាំងពីសម័យសង្គ្រាមម៉ោ គ្មានអ្នកណាបង្ខំថាឲ្យខ្ញុំជួយខាងណាខាងណានោះទេ ខ្ញុំនឹកឃើញថាកាលសម័យតស៊ូខ្មែរក៏វៃខ្មែរនឹងខ្មែរ ដល់សម័យប៉ុាវ៉ាក៏នៅតែខ្មែរវៃខ្មែរ ខ្ញុំឈប់ហើយខ្ញុំទៅផ្ទះហើយ ខ្ញុំក៏ម៉ោជួបប្រពន្ធកូនខ្ញុំទៅ ។

ប៊ុនថន៖ ចុះអ្នកភូមិអីដល់ពេលនេះទៅយ៉ាងម៉េចដែរ ខាងសន្តិសុខអីចឹង?

សាវឿន៖ ម៉ោខ្ញុំប្រាប់ឃុំគេ ប្រាប់ភូមិ ប្រាប់សន្តិសុខគេថាខ្ញុំមកនៅវិញហើយ ខ្ញុំសារភាពហើយ ដល់នេះគេឲ្យឲ្យខ្ញុំរស់នៅទៅ គេឲ្យខ្ញុំធ្វើចំការអីទៅ ខ្ញុំក៏រស់នៅធ្វើចំការចិញ្ចឹមប្រពន្ធកូនដក។

ប្រពន្ធ៖ មានតើ! កាលគេចូលម៉ោមានតើ!

ប៊ុនថន៖ ចុះដូចថាប៉ាវ៉ាអីចូលម៉ោចូលយូៗទេ?

សាវឿន៖ ទេវាម៉ោវៃតែមួយប្រាវទេ! គ្រាន់មកលួចឆ្មក់មកបាញ់ឆ្មក់ម៉េចគេថាសង្គ្រាមឈ្លបណាក់ ។

ប៊ុនថន៖ ប៉ុន្តែដំបូងខាងកងទ័ពវៀតណាម....

សាវឿន៖ ដល់៧៩ ។

ប៊ុនថន៖ បាទ!

សាវឿន៖ ដល់នេះមកបើកឃ្លាំងអង្ករ ឃ្លាំងស្រូវឲ្យប្រជាជនចែកប្រជាជន។

ប៊ុនថន៖ បាទ!

សាវឿន៖ ប្រជាជនក៏បានមានជីវិតរស់នៅ ព្រោះបានកងទ័ពវៀតណាមចូលម៉ោក្នុងភូមិបន្ទាយឆ្មានេះ នៅឆ្នាំ៧៩ណ្ហឹង ។

ប៊ុនថន៖ បាទ!

សាវឿន៖ គេបើកឃ្លាំងអង្ករ ឃ្លាំងអង្ករគេសុទ្ធតែចាក់សោ កងទ័ពវៀតណាមយកដំបងទៅឃ្លាំងអង្ករ បានចែកប្រជាជនហូបបានមានជីវិតរស់នៅ ។

ផល្លា៖ ចុះពូនៅប៉ាវ៉ាប៉ុន្មានឆ្នាំណ្ហឹងបានតួនាទីអីដែរពូ នៅច្រើនឆ្នាំដែរ តួនាទីពូនៅប៉ាវ៉ាមានតួនាទីអីដែរ ទាហានធម្មតាឬក៏...?

ប្រពន្ធ៖ គាត់មានបាននៅយូណាក់ នៅបានមួយប្រាវណ្ហឹង ។

សាវឿន៖ ខ្ញុំធ្វើបាន៥,៦ឆ្នាំដែរតើ!

ផល្លា៖ ៧៩បែកខ្មែរក្រហម?

សាវឿន៖ បាទបែកខ្មែរក្រហម ខ្ញុំចូលទៅខាងប៉ាវ៉ានៅឆ្នាំ៧៦ ។

ប៊ុនថន៖ ហើយរាល់ថ្ងៃមានកូនប៉ុន្មាននាក់?

សាវឿន៖ មានកូន៥នាក់ ។

ប៊ុនថន៖ អញ្ចឹងខ្ញុំអត់មានអីសួរពូទៀតទេ អរគុណច្រើនពូ ។

**ចប់**